**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខ:០១៦/០៩ រប.កកចយ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មិថុនា ឆ្នាំ ២០០៩ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែមិថុនា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវ ខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

### ក. ការងាររដ្ឋបាល

- ផ្ញើសេចក្តីសម្រេចលេខ ០៣៥/០៩ សរ.កកចយ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៩ “សេចក្តីសម្រេច ស្តីពី ការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

- ផ្ញើលិខិត០៣៤/០៩លអ.កកចយ ចុះថៃទី២២ ខែមិថុនា ឆ្នាំ២០០៩ អញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា នៅថ្ងៃអង្គារ៍ ទី២៥ ខែសីហា ឆ្នាំ២០០៩ នៅក្រសួងយុត្តិធម៌។

- ផ្ញើលិខិតជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីការស្នើរសុំឯកសារសង្ខេបពាក់ព័ន្ធនឹងជំនួយរបស់រាជរដ្ឋាភិបាលបារាំងកន្លងមក និងសំណូមពរ ដែលចង់អោយរដ្ឋាភិបាលបារាំងផ្តល់ជំនួយបន្ត។

- ផ្ញើលិខិតជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សំណើសុំត្រៀមបទអន្តរាគមន៍ ស្តីពីសមិទ្ធិផលនានា ដែលពាក់ព័ន្ធនិងការកែទម្រង់ច្បាប់ និងតុលាការនិងឯកសារមួយចំនួនសម្រាប់ធ្វើការផ្សព្វផ្សាយ។

- ផ្ញើលិខិតជូនឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សំណើសុំត្រៀមបទអន្តរាគមន៍ ស្តីពីសមិទ្ធិ ផលនានាដែលពាក់ព័ន្ធ និងការកែទម្រង់ច្បាប់ និងតុលាការនិងឯកសារមួយចំនួនសម្រាប់ធ្វើការផ្សព្វផ្សាយ។

- ផ្ញើលិខិតជូនឯកឧត្តម ទេព ដារ៉ុង ប្រធានរាជបណ្ឌិសភាវិជ្ជាជីវៈតុលាការ សំណើសុំត្រៀមបទអន្តរាគមន៍ ស្តីពីសមិទ្ធិផលនានាដែលពាក់ព័ន្ធ និងការកែទម្រង់ច្បាប់ និងតុលាការនិងឯកសារមួយចំនួនសម្រាប់ធ្វើការផ្សព្វផ្សាយ។

- ផ្ញើលិខិតជូនឯកឧត្តម ជីវ កេង ប្រធានសាលាដំបូងរាជធានីភ្នំពេញ សំណើសុំត្រៀមបទអន្តរាគមន៍ ស្តីពីសមិទ្ធផលនានាដែលពាក់ព័ន្ធ និងការកែទម្រង់ច្បាប់ និងតុលាការនិងឯកសារមួយចំនួនសម្រាប់ធ្វើការផ្សព្វផ្សាយ។

- ផ្ញើលិខិតជូនឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សំណើសុំត្រៀមបទអន្តរាគមន៍ស្តីពីសមិទ្ធផលនានាដែលពាក់ព័ន្ធ និងការកែទម្រង់ច្បាប់ និង តុលាការនិងឯកសារមួយចំនួនសម្រាប់ធ្វើការផ្សព្វផ្សាយ។

- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ ។

- ទទួលលិខិតលេខ ៩០៧ សជណ.រប ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៩ ស្តីការផ្លាស់ប្តូរថ្ងៃ និងពេលវេលាទទួលដំណើរមាតុភូមិនិវត្តន៍ របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង លោកជំទាវ ព្រមទាំងប្រតិភូ មកពីប្រទេសអេស្ប៉ាញ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៤៥នាទី (យន្តហោះចុះចត) នោះត្រូវបានលើកទៅ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៩ វេលាម៉ោង ០៨ៈ៤៥នាទី (យន្តហោះចុះចត )វិញ។

- ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងធម្មការនិងសាសនាដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃពុធ ទី២៤ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាង សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃព្រហស្បតិ៍ ទី២៥ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីប្រកាសតែងតាំង និងចូលកាន់តំណែងអគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍នៅថ្ងៃព្រហស្បតិ៍ ទី២៥ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទី ។

- ទទួលលិខិតអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីប្រកាសតែងតាំង និងចូលកាន់តំណែងអគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូលថ្ងៃសុក្រ ទី២៥ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទី ។

- ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃសុក្រ ទី ០៣ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- ទទួលលិខិតអញ្ជើញចូលរួម អង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការ បង្កើតតំបន់ការពារ និងអភិរក្សជីវចម្រុះ “សីមា” ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ទី ០២ ខែ កក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតអញ្ជើញចូលរួម អង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និង ការប្រើប្រាស់អគារសហកម្មសិទ្ធិដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ទី ២៤ ខែមិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ១៥ៈ០០នាទី នៅ ទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈ ដោយឡែកក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ អង្គារ៍ ទី ២៣ ខែមិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ៨ៈ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់សារ និងរូបភាព ព្រមានសុខភាពលើផលិតផលថ្នាំជក់ ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃច័ន្ទ ទី២២ ខែមិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ១៥ៈ០០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- បានទទួលលិខិតអញ្ជើញចូលរួមក្នុងពិធីប្រកាសផ្សព្វផ្សាយសារាចរ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលរៀបចំឡើងដោយស្រួងផែនការ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។

- ទទួលលិខិតអញ្ជើញជាកិត្តិយស ក្នុងពិធីជូនដំណើរ និងទទួលមាតុភូមិនិវត្តន៍ របស់គណៈប្រតិភូជាន់ខ្ពស់ដឹកនាំ ដោយឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវទៅចូលរួម កិច្ចប្រជុំលើកទី៣៣ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅទីក្រុងសេវីយ៉ា ប្រទេសអេស្ប៉ាញ ដែលនឹងប្រព្រឹត្ត ទៅនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី និងមាតុភូមិនិវត្តន៍ នៅថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០០៩ ។

- ទទួលសេចក្តីសម្រេចលេខៈ៥៧ សសរ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការបែង ចែកជំនាញ និងប៉ុស្តិ៍ សម្រាប់សិស្សថៅក្រមជំនាន់ទី៣ នៃរាជបណ្ឌិសភា វិជ្ជាជីវៈតុលាការឱ្យទៅបំរើការងារនៅតាមសាលា ដំបូងនិងអយ្យការអមសាលា ដំបូងរាជធានី-ខេត្ត ពីសាលារាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

- បានទទួលប្រកាសលេខៈ ៥១កយ/បក/០៩ ពីក្រសួងយុត្តិធម៌ ប្រកាសស្តីពីការបង្កើតក្រុមការងារ តុលាការ គំរូ របស់ក្រសួងយុត្តិធម៌ ចុះនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៩ )។

- បានទទួលលិខិតអញ្ជើញពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ កម្រិតនយោបាយ (Policy Dialogue) រវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលជប៉ុន ស្តីពីកិច្ចសហប្រត្តិបត្តិការសម្រាប់អភិវឌ្ឍន៍ ដែលនឹងប្រព្រឹត្ត ទៅនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ចាប់ពីម៉ោង០៩ៈ០០ នៅវិមានរដ្ឋាភិបាល(ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ) ។

- បានទទួលលិខិតអញ្ជើញពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលា ចូលរួមក្នុង “ពិធីចុះហត្ថលេខាលើអនុស្សារណៈ សហប្រត្តិបត្តិការរវាងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងឧត្តមក្រុមប្រឹក្សាសារការីនៃសាធារណៈរដ្ឋបារាំង ” ក្រោមអធិបតីភាពឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០នាទី រសៀលនៅសាលារាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

- បានទទួលលិខិត លេខៈ៣០៨/គ.ម/០៩ ចុះថ្ងៃទី០២ ខែមិថុនាឆ្នាំ២០០៩ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការឈរឈ្មោះជាបេក្ខភាពសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី៦ (២០០៦-២០១០ )។

- ទទួលលិខិតអញ្ជើញជាកិត្តិយស ក្នុងពិធីរំឭកខួបអនុស្សាវរីយ៍លើកទី១៩ ស្តីពីការប្រកាសបង្កើតវរសេនាតូច ២៤៦ (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩០-ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ )ក្រោមអធិបតីភាពរបស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ដែលនឹងប្រព្រឹត្ត

ទៅនៅថ្ងៃទី១៥ ខែមិថុនាឆ្នាំ២០០៩ វេលាម៉ោង ០៧ៈ៤៥ នាទី នៅទីបញ្ជាការកងឯកភាពអង្គរក្សជួរមុខខេត្តព្រះវិហារ។

- បានទទួលលិខិត៨០០.លស ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការរៀបចំរបាយការណ៍ ជូនសម្តេចអគ្គសេនាបតីតេជោនាយករដ្ឋមន្ត្រីអោយបានមុនថ្ងៃទី ១០ កក្កដា ឆ្នាំ២០០៩រួមទាំង ្យរៀចតចៀផយ។

- ទទួលលិខិតអញ្ជើញជាកិត្តិយសក្នុងពិធីសម្ភោធ ការជួសជុលបណ្ណាញអគ្គសនីនៅសារមន្ទីរជាតិ និង ប្រគល់ -ទទួល វត្ថុបូរាណពីសប្បុរសជន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ១៦ៈ០០ នាទីនៅ សារមន្ទីរជាតិ (ភ្នំពេញ)។

- ទទួលប្រកាសលេខ ៨៣ ប្រក.ជហ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ របស់ទីស្តីការ គណៈរដ្ឋ-មន្ត្រី ស្តីពីការបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលរបាយការណ៍ពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីកិច្ចប្រជុំអន្តរក្រសួង ស្តីពីការរៀបចំផែនការសកម្មភាពអភិបាលកិច្ចទី៣ ។

- ទទួលលិខិតអញ្ជើញចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ទី១០ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី និងថ្ងៃសុក្រ ទី ១២ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី នៅទីស្តីការ គណៈរដ្ឋមន្ត្រី។

- ទទួលរបាយការណ៍ លេខ ១២ ដនស/រប ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ របាយការណ៍បូកសរុបវាយតម្លៃលទ្ធផល និងសកម្មភាពការងារ ឆ្នាំ ២០០៨ និង ទិសដៅបន្ត។

- ទទួលលិខិតលេខ ៣៨៥.ផក ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៩ របស់ក្រសួងផែនការស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយជូនភ្ជាប់នូវសារាចរ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។

## ខ. ការងារកំណែទម្រង់

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការកាលពីថ្ងៃច័ន្ទ ទី១៥ ខែ មិថុនា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មាន រៀបចំកិច្ចប្រជុំមួយដើម្បី ពិភាក្សាផ្លាស់ប្តូរយោបល់ ជាមួយអនុប្រធានឧត្តមក្រុមប្រឹក្សាសារការី ប្រទេសបារាំង និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កាលពី ថ្ងៃទីពុធ ទី ១៥ ខែមិថុនា ឆ្នាំ២០០៩។

- កិច្ចប្រជុំផ្ទៃក្នុងដឹកនាំដោយ ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដើម្បីអនុវត្តសារាចររបស់រាជ រដ្ឋាភិបាលកាលពីថ្ងៃពុធ ទី ២៤ ខែមិថុនា ឆ្នាំ ២០០៩។

- បានរៀបចំសេចក្តីសម្រេចលេខៈ០៣៥/០៩ សរ.កកចយ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីរការបង្កើត ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

- ក្រុមគម្រោងនីមួយៗរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំ និងធ្វើផែនការការងារសម្រាប់ឆ្នាំ២០០៩។

## គ. ផ្សេងៗ

- ចូលរួមអង្គប្រជុំអន្តរក្រសួងផ្សេងៗ។

- បានចូលរួមក្នុងអង្គសិក្ខាសាលាក្នុងពិធីប្រកាសផ្សព្វផ្សាយសាធារណៈ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន ២០០៩-២០១៣ ដែលរៀបចំដោយក្រសួងផែនការកាលពីថ្ងៃទី ២៣ ខែមិថុនាឆ្នាំ២០០៩ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។

- កិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍មួយចំនួន ដើម្បីរៀបចំអត្ថបទបញ្ចូល ក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ កាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

## ២-សន្និដ្ឋាន

ក្នុងខែ មិថុនា ឆ្នាំ ២០០៩ នេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយ មានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំកិច្ចក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដោយផ្តោតសំខាន់ទៅលើគម្រោងតុលាការគំរូ និង ពិភាក្សាអំពីការផ្ទេរគម្រោង តុលាការគំរូដែលស្ថិតនៅក្នុងគម្រោងរបស់ អគ្គលេខាធិការ-ដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ទៅ ក្នុងគម្រោងរបស់ក្រសួងយុត្តិធម៌ និងអំពីការស្នើរសុំថវិការបន្ថែមដោយក្រសួងយុត្តិម៌ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ របស់តុលាការគំរូ។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ក៏មានគម្រោងរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជាដោយផ្តោតទៅលើភាពរីកចំម្រើន នៃការអនុវត្តគម្រោងក្នុងត្រីមាសទី១ និងត្រីមាសទី២ និងអំពីសំណើកែតម្រូវផែនការសកម្មភាព និងថវិការប្រចាំឆ្នាំ២០០៩ នៅថ្ងៃអង្គារ៍ ទី២៥ ខែសីហា ឆ្នាំ២០០៩ នៅទីស្តីការក្រសួងយុត្តិធម៌ ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

- បន្តអនុវត្តគម្រោងតុលាការគំរូ
- បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន
- បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្តីពីមុខងារ ស្ថាប័នរដ្ឋ
- ត្រៀមរៀបចំសន្និសិទជាតិស្តីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៨ ។
- ត្រៀមរៀបចំទស្សនកិច្ចសិក្សាដើម្បីស្វែងយល់អំពីយន្តការអំប៊ុស្មាន់ Ombudsman នៅប្រទេសជិតខាងមួយ នៅសប្តាហ៍ទី៤ ខែកក្កដា ឆ្នាំ២០០៩ ។

រាជធានី ភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩

**អ្នកធ្វើរបាយការណ៍**

**ស៊ុន សិរីវុធ**

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**